## ទ្រឹស្តី នៃការកាត់ទោស ឬការធ្វើបត្យាប័ន (Aut Dedere Aut Judicare)

ពាក្យនេះបង្ហាញអំពី ជម្រើសកាតព្វកិច្ច នៃការកាត់ទោសជនល្មើស ឬ ធ្វើបត្យាប័នគាត់ទៅក្រៅប្រទេស ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនៅទីនោះ។ កាតព្វកិច្ចនេះ មានចែងក្នុង សន្ធិសញ្ញាទ្វេភាគី ឬពហុភាគី។ ទោះបីជាមានអត្ថន័យជាន់គ្នារវាងវា នឹងយុត្តាធិការសកល (universal jurisdiction) កាតព្វកិច្ចទាំងពីរនេះ នៅតែមានចំណុចខុសគ្នាខ្លះ។

Aut Dedere Aut Judicare អនុវត្តសម្រាប់តែប្រភេទ បទឧក្រិដ្ឋមួយចំនួនក្រោមច្បាប់អន្តរជាតិ ដូចជាការបំពានធ្ងន់ធ្ងរ (grave breaches) នៃអនុសញ្ញាទីក្រុងហ្សឺណែវ (Geneva Conventions of 1949)។ ដោយសារ ដំណើរបត្យាប័ន ទាញចេញពីផ្នែកនៃទ្រឹស្តីនេះស្រដៀងគ្នានឹងដំណើរការបត្យាប័ន មានភាពស្មុគស្មាញ សហគមអន្តរជាតិ បានប្រើប្រាស់វិធានការផ្សេងមួយទៀត ដែលមានលក្ខណៈងាយស្រួល គឺការប្រគល់ខ្លួន (surrender)។

គណៈកម្មការច្បាប់អន្តរជាតិ (international law commission: ILC) របស់អង្គការសហប្រជាជាតិ បានធ្វើការសិក្សាអំពីទ្រឹស្តីនេះ នឹងបានចេញរបាយការណ៍ ក្នុងឆ្នាំ ២០០៧ (UN Doc. A/CN.4/585) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p.253)។